**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-សជណ.docx/ 27-11-19/ស៊ីយៀង-បល-P.167

**អគ្គិសនីកម្ពុជា**

លេខ: ២៩៦២ អជក.អក.រប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ២១ រូប** ដើម្បីចូលបម្រើការងារនៅ តាមបណ្តាអង្គភាព-អគ្គិសនីខេត្ត នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*-**<u>លក្ខណៈសម្បត្តិបេក្ខជន</u>** :

**១- បុគ្គលិកព័ត៌មានវិទ្យា អគ្គិសនីខេត្តព្រះសីហនុ** ចំនួន ០១ រូប :

- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រព័ត៌មានវិទ្យា ឡើងទៅ ។

**២- ភ្នាក់ងារ ថែទាំបណ្តាញMV ស្នាក់ការឃុំស់អាង អគ្គិសនីស្ទឹងត្រែង** ចំនួន ០១ រូប

- **ភ្នាក់ងារថែទាំបណ្តាញMV-LV** ( **ស្នាក់ការជូនសរ, ស្នាក់ការសង្កែ, ស្នាក់ការត្រើសនិងស្នាក់ការសំយ៉ោង អគ្គិសនីស្វាយរៀង** ) ចំនួន ០៧ រូប
- **ភ្នាក់ងារថែទាំបណ្តាញMV-LV ស្នាក់ការកោះពីរ អគ្គិសនីកំពង់ចាម** ចំនួន ០១ រូប
- **បុគ្គលិកប្រចាំការ អនុស្ថានីយសៀមរាប អង្គភាពបណ្តាញបញ្ជូន** ចំនួន ០៤ រូប :
- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ ។

**៣-ភ្នាក់ងារត្រួតពិនិត្យ អគ្គិសនីកំពង់ចាម** ចំនួន ០១ រូប

- **ភ្នាក់ងារត្រួតពិនិត្យ អគ្គិសនីសៀមរាប** ចំនួន ០៣ រូប
- **បុគ្គលិក ខណ្ឌបច្ចេកទេសនិងផែនការផ្គត់ផ្គង់សម្ភារ និងខណ្ឌត្រួតពិនិត្យបរិក្ខារអគ្គិសនី អង្គភាពបណ្តាញបញ្ជូន** សរុបចំនួន ០៣រូប
- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា វិស្វករអគ្គិសនី ឡើងទៅ ។

*- **<u>បញ្ជាក់</u>** : ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺផ្តល់អាទិភាពជូន

- ជនពិការ ( សម្រាប់មុខងារលេខរៀងទី១ )
- បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន មានអាសយដ្ឋានស្ថិតនៅខេត្តសាមី ។

***- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក( Download ) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។**

***- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។**

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ចំនួន ០១ ច្បាប់

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ ហូតដល់ថ្ងៃទី**២៩** ខែធ្នូ ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃព្រហស្បតិ៍ ០៩ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**កែវ_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានថ្មីៗ " ។